រាជរដ្ឋាភិបាលកម្ពុជា

**គជអប NCDD** គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# វឌ្ឍនភាពកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០១៥

ផែនការសកម្មភាព ឆ្នាំ២០១៥ របស់ គ.ជ.អ.ប បានកំណត់នូវចំណុចដៅជាអាទិភាពចំនួន២០។ ថវិកាចំណាយសរុបចំនួនប្រមាណ៣២៦លានដុល្លារ (ថវិការដ្ឋចំនួនប្រមាណ៨៥% និងថវិកាគាំទ្រពីដៃគូចំនួនប្រមាណ១៥%)។ ស្ថាប័នអនុវត្តគឺ ក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិចំនួន២១ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។

ជារួម ក្នុងចំណោមចំណុចដៅជាអាទិភាពចំនួន២០ មានចំណុចដៅចំនួន១៦ ឬស្មើនឹង៨០%ត្រូវបានអនុវត្តនិងបានសម្រេចតាមចំណុចដៅទាំងស្រុង ឬស្មើរតែទាំងស្រុង។

## ១. ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

១. ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាន
- បានសិក្សា និងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រទំនាក់ទំនងស្តីពីការចែករំលែកព័ត៌មាន

២. ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានសិក្សា និងកែលំអនីតិវិធីហិរញ្ញវត្ថុរបស់លេខាធិការដ្ឋានក្នុងការផ្តល់ថវិកាគាំទ្រដល់ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ
- បានរៀបចំសេចក្តីព្រាងនៃសេចក្តីណែនាំស្តីពីនីតិវិធីរៀបចំគោលនយោបាយ ដើម្បីធានាដល់ការលើកកម្ពស់ភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា
- បានកែលំអនីតិវិធីកិច្ចប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយស្ថាប័នអនុវត្ត
- បានសិក្សាវាយតម្លៃស្ថានភាពការងាររបស់មន្ត្រី និងទីប្រឹក្សាបច្ចេកទេសទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរៀបចំផែនការបុគ្គលិកសម្រាប់ឆ្នាំ២០១៦ ព្រមទាំងពិនិត្យកែសម្រួលតួនាទី ភារកិច្ចរបស់មន្ត្រី និងទីប្រឹក្សាទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

## ២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

៣. ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម
- បានបង្កើតគណៈកម្មាធិការគ្រប់គ្រង និងបានអនុវត្តការងារគណនេយ្យភាពក្នុងស្រុកចំនួន២៧

៤. ការរៀបចំ និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក
- បានរៀបចំសេចក្តីណែនាំ និងគំរូវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក
- ក្រុង ស្រុកចំនួន៥៤បានរៀបចំ និងអនុម័តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន



៥. ការពង្រឹងសមត្ថភាពសមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានបង្កើតអគ្គលេខាធិការដ្ឋានរួម និងបានរៀបចំយុទ្ធសាស្ត្រថ្មីដើម្បីពង្រឹងប្រសិទ្ធភាពការងារ

៦. ការរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌ
- បានរៀបចំ អនុម័ត និងបានបណ្តុះបណ្តាល

៧. ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង
- បានរៀបចំកម្មវិធីតាមប្រព័ន្ធកុំព្យូទ័រ និងបានអនុវត្តសាកល្បងនៅតាមក្រុង ស្រុកចំនួន១០។

## ៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

៨. ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំបញ្ចប់សេចក្តីព្រាងលក្ខន្តិកៈដោយឡែក សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៩. ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីការងារយេនឌ័រ
- រដ្ឋបាលខេត្តចំនួន៣បានរៀបចំបញ្ចប់វគ្គបណ្តុះបណ្តាល និងខេត្តមួយចំនួនផ្សេងទៀតកំពុងដំណើរការរៀបចំជាបន្តបន្ទាប់

១០.ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្តទាំងអស់បានរៀបចំបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស
- មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តបានចាប់ផ្តើមដំណើរការតាមតួនាទីដែលបានកំណត់

## ៤. ការផ្ទេរមុខងារ និងធនធាន

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

១១.ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក
- បានធ្វើប្រតិភូកម្មមុខងារការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅឱ្យខេត្ត ក្រុង ស្រុក ឃុំ (ខេត្តបាត់ដំបង)
- បាន និងកំពុងសិក្សាដើម្បីរៀបចំលិខិតបទដ្ឋានសម្រាប់ការផ្ទេរមុខងារគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ
- បាននិងកំពុងផ្ទេរសាកល្បងនូវមុខងារគ្រប់គ្រងមណ្ឌលសុខភាព ការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងសេវាអប់រំអនាម័យជនបទ

១២.ការផ្ទេរមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាទីប្រជុំជនឱ្យទៅរដ្ឋបាលក្រុង
- បានសិក្សាអំពីលទ្ធភាព និងជម្រើសនានាក្នុងការផ្ទេរមុខងារសេវាទីប្រជុំជនពីរដ្ឋបាលខេត្តឱ្យទៅរដ្ឋបាលក្រុង

១៣.ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពីមុខងារជាជម្រើស និងសេវាសង្គម
- បានរៀបចំបញ្ចប់សេចក្តីព្រាងឯកសារបច្ចេកទេស

## ៥. វិមជ្ឈការហិរញ្ញវត្ថុ

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

១៤.ការកែលំអប្រព័ន្ធ និងនីតិវិធីអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់
- បានរៀបចំក្រុមការងារអន្តរក្រសួងដើម្បីចុះសិក្សាស្រាវជ្រាវ ប្រមូលនូវព័ត៌មាន និងកំណត់នូវបញ្ហាប្រឈមនានា ដើម្បីឈានទៅធ្វើការកែលំអប្រព័ន្ធ និងនីតិវិធីនៃការផ្ទេរ និងការប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យកាន់តែល្អប្រសើរ

១៥.ការបង្កើតលេខាធិការដ្ឋានទទួលបន្ទុកមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះនឹងផ្តល់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

១៦.ការកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សម្រាប់ការប្រឹក្សាយោបល់។

Sida | unicef | ADB | giz | IFAD | UNDP

**លេខាធិការដ្ឋាន គ.ជ.អ.ប៖** ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ:+855 (0)23 362 175 , +855 (0) 23 720 038
អ៊ីមែល: info@ncdd.gov.kh គេហទំព័រ: www.ncdd.gov.kh